# សេវាសម្រាប់កុមារ

ទស្សនវិទ្យារបស់យើងក្នុងការបង្រៀន គឺជាការដាំដុះ និង បង្កុលក្ខណ:អំណោយផលដល់គ្រាប់ពូជដើម្បីឱ្យ លូតលាស់ និង កំណត់ទិសដៅអនាគត។ យើងជឿទៅលើការបង្រៀនតាមរយ:បទពិសោធន៍ជាច្រើន ដែល ផ្តល់នូវភាពរីករាយ ការអប់រំ ភាពច្នៃប្រឌិត និង មានភាពបើកចំហរ ដែលកុមារអាចទទួលបាននូវទំនុកចិត្ត និងកសាងទំនុកចិត្តរបស់ពួកគេ។ ចំនុចនេះរួមមានសកម្មភាពខាងក្នុង និងខាងក្រៅថ្នាក់រៀន ព្រមទាំងបទពិសោធន៍នៃការលេងកម្សាន្តដែលបានគ្រោងទុក ដែលផ្តល់ឱ្យកុមារនូវឱកាសក្នុងការអភិវឌ្ឍន៍បំណិនផ្នែកសង្គម សីលធម៌ ទំនាក់ទំនង ការគិតគូពិចារណា និង បំណិនផ្លូវកាយរបស់ពួកគេ។

**CORE**សាលាមត្តេយ្យសហគមន៍ ផ្តល់នូវកម្មវិធីអប់រំដោយផ្អែកលើសេចក្តីត្រូវការអភិវឌ្ឍន៍ ចំណាប់អារម្មណ៍ និងបទពិសោធន៍របស់កុមារនីមួយៗ។ យើងគាំទ្រដល់ការអភិវឌ្ឍន៍សតិបញ្ញា និងភាសារបស់កុមារ និង ផ្តល់ នូវមូលដ្ឋានមួយដ៏រឹងមាំ សម្រាប់ការរៀនសូត្រពេញមួយជីវិត។យើងធ្វើការងារដោយមានកិច្ចសហការជាមួយអង្គការនានា ដើម្បីផ្តល់ឱ្យកូនរបស់អ្នកនូវការថែទាំ ការគោរព និង ការផ្តល់ភាពអង់អាច ដែលពួកគេត្រូវការដើម្បីឱ្យមានអនាគតល្អ។

សាលាមត្តេយ្យរបស់យើងទទួលបានថវិការដ្ឋគាំទ្រពីក្រសួងអប់រំ។ យើងកំណត់យកថ្លៃសិក្សាទាប ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់មូលដ្ឋានCabramatta។សាលាមត្តេយ្យរបស់យើងផ្តោតលើកុមារដែលមានសាវតារវប្បធម៌ និង ភាសាចម្រុះ និងជាកុមារដែលជួបការលំបាក ព្រមទាំងបម្រើចំពោះកុមារមួយចំនួនដែលមានសេចក្តីត្រូវការបន្ថែម។

សាលាមត្តេយ្យរបស់យើងមានទីតាំងស្ថិតនៅកែងផ្លូវ **Railway Parade** និង ផ្លូវ **McBurney** (ស្ថិតនៅចន្លោះ បណ្ណាល័យ **Whitlam** និង ការិយាល័យកណ្តាល**CORE Community Services**) និងចាប់បើកពីថ្ងៃ**ច័ន្ទ** ដល់ថ្ងៃ**សុក្រ** ពីម៉ោង **៩:០០** ព្រឹក ដល់ម៉ោង **៣:៣០**រសៀល។

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងដើម្បីពិនិត្យមើលកន្លែងរបស់យើង និង ជួបជាមួយបុគ្គលិករបស់យើង ឬ ដើម្បីទទួលបានព័ត៍មានបន្ថែម សូមទាក់ទងយើងខ្ញុំតាមរយ: ៖

**ទូរស័ព្ទ ៖(02) 97278723**
**Email: chn@corecs.org.au**

កុមារពីវប្បធម៌និងប្រវត្តិនិង ខុសៗគ្នាបាត់បង់ប្រយោជន៍
៧ត៧យ៩ផផិា◌ិផ០